# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៣១ សសរ

## សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការអន្តរក្រសួង
## ដើម្បីរៀបចំព្រះរាជពិធីបួងសួងចម្រើនសេចក្តីសុខ ជូនដល់ព្រះរាជាណាចក្រកម្ពុជា
## នៅមុខប្រាសាទអង្គរវត្ត ខេត្តសៀមរាប នៅថ្ងៃទី១១-១២ ខែមេសា ឆ្នាំ២០២៥

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួងរៀបចំព្រះរាជពិធីបួងសួងចម្រើនសេចក្តីសុខ ជូនដល់ព្រះរាជាណាចក្រកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១-សម្តេចមហាមន្ត្រី **គុយ សុផល** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង និងជាប្រធានគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ | ប្រធាន |
| ២-ឯកឧត្តម **ហ៊ុន ម៉ានី** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងជាប្រធានសហភាពសហព័ន្ធយុវជនកម្ពុជា | អនុប្រធាន |
| ៣-ឯកឧត្តម **ឈិន កេតនា** | អនុប្រធានអចិន្ត្រៃយ៍ និងជាអគ្គលេខាធិការ គ.ជ.ប.អ. មានឋានៈ និងបុព្វសិទ្ធិស្មើ ឧបនាយករដ្ឋមន្ត្រី | អនុប្រធានអចិន្ត្រៃយ៍ |

៤-លោកអ្នកឧកញ៉ាមហាភក្តី **គង់ បញ្ញា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការទូទៅ

អមក្រសួងព្រះបរមរាជវាំង អនុប្រធាន

៥-លោកជំទាវបណ្ឌិតសភាចារ្យ **ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ អនុប្រធាន

៦-ឯកឧត្តម **ចាយ បូរិន** រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា អនុប្រធាន

៧-ឯកឧត្តម **ហួត ហាក់** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ អនុប្រធាន

៨-ឯកឧត្តម **នេត្រ ភក្ត្រា** រដ្ឋមន្ត្រីក្រសួងព័ត៌មាន អនុប្រធាន

៩-ឯកឧត្តម **ប្រាក់ សោភ័ណ** អភិបាល នៃគណៈអភិបាលខេត្តសៀមរាប អនុប្រធាន

១០-ឯកឧត្តមសន្តិបណ្ឌិត **យូ ស៊ុនឡុង** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី សមាជិក

១១-លោកជំទាវ **ហ៊ីន ម៉ាណា** អគ្គនាយិកា នៃអគ្គនាយដ្ឋានវិទ្យុ និងទូរទស្សន៍បាយ័ន សមាជិកា

១២-ឯកឧត្តម **សេង ទៀង** អនុប្រធានគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ

និងជារដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

១៣-ឯកឧត្តម **គង់ សោភ័ណ** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ សមាជិក

១៤-ឯកឧត្តម **ជូ គីមឡេង** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

១៥-ឯកឧត្តមនាយឧត្តមសេនីយ៍ **វង្ស ពិសេន** អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ សមាជិក

១៦-ឯកឧត្តមនាយឧត្តមសេនីយ៍ **ស ថេត** អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ សមាជិក

១៧-ឯកឧត្តមនាយឧត្តមសេនីយ៍ **ឥត សារ៉ាត់** អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ

នាយសេនាធិការចម្រុះ សមាជិក

១៨-ឯកឧត្តមនាយឧត្តមសេនីយ៍ **សៅ សុខា** អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ

មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក

១៩-ឯកឧត្តមនាយឧត្តមសេនីយ៍កិត្តិសង្គហបណ្ឌិត **ហ៊ីង ប៊ុនហៀង** អគ្គមេបញ្ជាការរង

នៃកងយោធពលខេមរភូមិន្ទ មេបញ្ជាការនៃ

បញ្ជាការដ្ឋានកងអង្គរក្ស សមាជិក

២០-ឯកឧត្តមនាយឧត្តមសេនីយ៍ **ម៉ៅ សុផាន់** អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ

មេបញ្ជាការកងទ័ពជើងគោក សមាជិក

២១-ឯកឧត្តម **សៀង ឈុនទ្រី** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

២២-ឯកឧត្តម **ឃី សុវណ្ណរតនា** រដ្ឋលេខាធិការក្រសួងការបរទេស

និងសហប្រតិបត្តិការអន្តរជាតិ សមាជិក

២៣-ឯកឧត្តម **ឱម គីមស៊ា** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក

២៤-លោកជំទាវ **គីម សេដ្ឋានី** រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា សមាជិកា

២៥-ឯកឧត្តម **លី រស្មី** រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម

និងសំណង់ សមាជិក

២៦-ឯកឧត្តម **ភឹម គុណាវឌ្ឍន៍** រដ្ឋលេខាធិការក្រសួងព័ត៌មាន សមាជិក

២៧-ឯកឧត្តម **សាន់ សាប់អី** រដ្ឋលេខាធិការក្រសួងសុខាភិបាល សមាជិក

២៨-លោកជំទាវ **ឡុងឌី សាន់ណារ៉ា** រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិកា

២៩-ឯកឧត្តម **សោម រតនា** រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា សមាជិក

៣០-ឯកឧត្តម **សាម៉ន បណ្ឌិត្យ** រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល សមាជិក

៣១-អ្នកឧកញ៉ាកត្តិព្រះស្តេច **ហេង គីមគុណា** ទីប្រឹក្សាក្រសួងព្រះបរមរាជវាំង សមាជិក

៣២-ឯកឧត្តម លោកជំទាវ អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត សមាជិក

**ប្រការ២ ._**

គណៈកម្មការអន្តរក្រសួងនេះ មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ដឹកនាំ រៀបចំ ចាត់ចែង សម្របសម្រួលជាមួយស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ដើម្បីឱ្យដំណើរការនៃការរៀបចំព្រះរាជពិធីប្រព្រឹត្តទៅបានល្អ
- រៀបចំគម្រោងចំណាយផ្សេងៗ នៃដំណើរការក្នុងការរៀបចំព្រះរាជពិធី
- រៀបចំការពារសន្តិសុខ របៀបរៀបរយ សណ្តាប់ធ្នាប់ ចរាចរណ៍ និងធានាសុវត្ថិភាពឱ្យបានគ្រប់គ្រាន់ មុន-ក្រោយ ក្នុងពេលប្រារព្ធព្រះរាជពិធី និងតាមផ្លូវឆ្លងកាត់
- ទំនាក់ទំនង និងសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច ស្ថាប័នពាក់ព័ន្ធក្នុងការអញ្ជើញភ្ញៀវជាន់ខ្ពស់ជាតិ អន្តរជាតិចូលរួមក្នុងព្រះរាជពិធី
- ផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងការប្រារព្ធព្រះរាជពិធីឱ្យបានទូលំទូលាយ។

**ប្រការ៣ ._**

គណៈកម្មការនេះ មានសិទ្ធិបង្កើតអនុគណៈកម្មការ ឬក្រុមការងារបន្ថែមជាជំនួយការ និងប្រើប្រាស់មន្ត្រីក្រោមឱវាទតាមការចាំបាច់ ដើម្បីធានាឱ្យការរៀបចំព្រះរាជពិធីប្រព្រឹត្តទៅបានល្អប្រសើរ។

**ប្រការ៤ ._**

គណៈកម្មការនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ សម្រាប់ដំណើរការការងាររបស់ខ្លួន។

**ប្រការ៥ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៦កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៤ ខែមីនា ឆ្នាំ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ដូចប្រការ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ